ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# បច្ចេកទេសដាំដំណាំត្រសក់ចំណារ ដែលធន់ទៅ នឹងការប្រែប្រួលអាកាសធាតុ







ភ្នំពេញ ខែ ឧសភា ឆ្នាំ ២០១៧

IFAD
Investing in rural people

រៀបចំដោយ : កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ( ASPIRE)

ឧបត្ថម្ភដោយ : រាជរដ្ឋាភិបាលកម្ពុជា និងមូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍកសិកម្ម(IFAD)

# មាតិកា

ទំព័រ


មាតិកា ........ 1

សេចក្តីថ្លែងអំណរគុណ ........ 2

មេរៀនទី ១: ការជ្រើសរើសទីតាំង និងការរៀបចំដី ........ 3

មេរៀនទី ២: ការធ្វើរោងបណ្តុះកូន និងការបណ្តុះគ្រាប់ ........ 8

មេរៀនទី ៣: ការដាំកូនត្រសក់ ........ 11

មេរៀនទី៤ : របៀបស្រោចស្រពដោយប្រព័ន្ធដំណាក់ទឹក ........ 13

មេរៀនទី៥ : ការថែទាំ ........ 16

មេរៀនទី៦ : បច្ចេកទេសគ្រប់គ្រង ក្រោយការប្រមូលផលត្រសក់ ........ 20

មេរៀនទី ៧ : ការបញ្ចូលរបៀបថ្មី លើគោលគំនិត អាជីវកម្មកសិកម្មខ្នាតតូចផ្អែកដំណាំបន្លែ ........ 21

ឯកសារយោង ........ 29

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំសូមសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាលកម្ពុជា និងមូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍកសិកម្ម (IFAD) ដែលបានផ្តល់ហិរញ្ញប្បទានដល់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទក្នុងការអនុវត្ត កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ (ASPIRE) មានគោលបំណង កាត់បន្ថយភាពក្រីក្រ និងបង្កើនភាពធន់របស់គ្រួសារ កសិករ ខ្នាតតូចក្រីក្រ និងងាយរងគ្រោះនៅកម្ពុជា។ កម្មវិធីបានផ្តល់ថវិកា ដល់អគ្គនាយកដ្ឋានកសិកម្ម/នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ក្នុងការអនុវត្ត សមាសភាពទី២ នៃកម្មវិធីគឺ អភិវឌ្ឍសមត្ថភាពសេវាផ្សព្វផ្សាយកសិកម្ម ដើម្បីជួយគាំទ្រការកែលម្អសេវាផ្សព្វផ្សាយកសិកម្ម នៅថ្នាក់ក្រោមជាតិ និងមូលដ្ឋានតាមរយៈបង្កើនគុណភាពផ្សព្វផ្សាយកសិកម្ម និងគ្រប់គ្រងចំណេះដឹង និងពង្រឹងធនធាន មនុស្សសម្រាប់ផ្សព្វផ្សាយកសិកម្ម។

បម្រែបម្រួលអាកាសធាតុ មានការប្រែប្រួលខ្លាំង រដូវដែលផ្លាស់ប្តូរ បង្កឲ្យមានផលប៉ះពាល់ដល់ជីវភាព រស់នៅរបស់កសិករ និងផលប៉ះពាល់ដល់របរកសិកម្ម ទទួលប្រាក់ចំណូលទាបដូច្នេះហើយទើបកម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ រៀបចំឯកសារផ្តល់ចំណេះដឹងនេះឡើង ដើម្បីឆ្លើយតបនឹងបម្រែបម្រួលអាកាសធាតុ ឲ្យបានទាន់ពេលវេលា ដែលជាតម្រូវការរបស់កសិករខ្នាតតូចគ្រប់ៗគ្នា ទាំងក្នុងនឹងក្រៅគម្រោងផងដែរ ។

យើងសង្ឃឹមថាឯកសារនេះ និងជួយដល់ មន្ត្រីផ្សព្វផ្សាយ ភ្នាក់ងារផ្សព្វផ្សាយ បង្ហាត់ពីបច្ចេកទេសដាំដំណាំត្រសក់ចំណារដែលឆ្លើយតបទៅ នឹងការប្រែប្រួលអាកាសធាតុវាជាវិធីសាស្រ្តងាយៗ សាមញ្ញក្នុងផលិតកម្មដំណាំបន្លែដែលកសិករអាចធ្វើបាន និងទទួលប្រាក់ចំណូលកើនឡើង ។

ឯកសារណែនាំ "**បច្ចេកទេសដាំដំណាំត្រសក់ចំណារ ដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ**" នេះជា សមិទ្ធផលថ្មីមួយរបស់កម្មវិធី ASPIRE ភាពជោគជ័យក្នុងដំណើរការរៀបចំសៀវភៅនេះ គឺអាស្រ័យទាំងស្រុងលើកិច្ចសហប្រតិបត្តិការ និងការចូលរួមក្រុមការងារបច្ចេកទេស របស់កម្មវិធីនៃ អគ្គនាយកដ្ឋានកសិកម្ម/នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ។

# មេរៀនទី ១: ការជ្រើសរើសទីតាំង និងការរៀបចំដី

១. គោលបំណងនៃវគ្គបណ្តុះបណ្តា ផ្តល់ចំណេះដឹងដល់សិក្ខាកាមអំពីៈ

- ការរៀបចំដី ដាំដំណាំក្នុងរដូវប្រាំង និងវស្សា
- ការជ្រើសរើសគ្រាប់ពូជដែលធន់ និងការប្រែប្រួលអាកាសធាតុ ដើម្បីសាប និងទទួលបានកូនដំណាំយ៉ាងល្អសម្រាប់ស្ទូង
- សារៈប្រយោជន៍ ការគ្របកៅស៊ូ និងពង្រាយចំបើងលើរង ដំណាំ ដែលអាចទប់ទល់ នឹងការប្រែប្រួលអាកាសធាតុ

## ២. ការជ្រើសរើសទីតាំង

- ក្បែរប្រភពទឹក
- រដូវប្រាំង នៅក្បែរផ្ទះ ក្នុងស្រែក្រោយពីប្រមូលផលស្រូវ
- រដូវវស្សា ដីខ្ពស់មិនលិចទឹក ដីរាបស្មើ ឬជម្រាលមិនសូវខ្លាំង
- ដីធូរ មានជីជាតិល្អ ជ្រាបទឹកល្អ ជៀសវាងដីគ្រួស ដីឥដ្ឋ ដីខ្សាច់ដីជាតិអាចធ្វើឲ្យដីប្រសើរដោយ ជីក្រោល ឬកំប៉ុស្ត
- មានរបងព័ទ្ធជុំវិញ មិនឆ្ងាយពីផ្ទះ
- បង្ហូរទឹកចេញបាន ដីមិនសើមពេកនារដូវភ្លៀង ទីកន្លែងស្រឡះមានខ្យល់ល្អ

## ៣. ការជ្រើសរើសគ្រាប់ពូជ

- ពូជសុទ្ធអត្រាដុះលើសពី៨០ភាគរយ
- ពូជធន់និងអាកាសធាតុ សត្វល្អិត ជម្ងឺ
- អាយុកាលខ្លីសមស្របតាមតំបន់
- ផ្តល់ទិន្នផលខ្ពស់



ការរៀបចំសួនបន្លែ

## ៤. ការរៀបចំដី

### ការភ្ជួរដី

- ភ្ជួរដី ជម្រៅ ២តឹក ទៅ៣តឹក
- ភ្ជួរឲ្យបានម៉ត់ល្អ ហាលដី ១០-១៥ថ្ងៃ មុនដាំ ជួយៈ
- កម្ចាត់សត្វល្អិតចង្រៃ និងជម្ងឺ
- ដីធូ ខ្យល់ចេញចូលល្អ ឫសដុះលូតលាស់ខ្លាំង
- រក្សាសំណើមដីបានល្អ



ការភ្ជួររាស់រៀបចំដី

### លើករងដាំតាមរដូវ

- **រងរដូវវស្សា** : ខ្ពស់ជាខ្នងអណ្តើក
- **រងរដូវប្រាំង** : ទាប រាងដក់កណ្តាល
- **ទទឹង**: ១ម៉ែត្រ បណ្តោយ មិនលើសពី ២៥ម៉ែត្រ
- **រដូវវស្សា**: កម្ពស់រង ៣០ សង្ទីម៉ែត្រ-៥០សង្ទីម៉ែត្រ
- **ចន្លោះគុម្ព**: ៥០សង្ទីម៉ែត្រ
- **រដូវវស្សា**: ចន្លោះជួរ ៧៥ សង្ទីម៉ែត្រ
- **រដូវប្រាំង**: ចន្លោះជួរ ៥០ សង្ទីម៉ែត្រ

### ដាក់ជីទ្រាប់បាត

- ជីលាមកសត្វស្ងួត កាកសំណល់រុក្ខជាតិ (ស្លឹកឈើ សម្រាម)នឹងជីកំប៉ុស្ត ១,៣ គីឡូក្រាម ក្នុង១ម៉ែត្រការ៉េ ធ្វើឲ្យដីធូរ ឫសងាយដុះលូតលាស់ កូនបន្លែដុះលូតលាស់ឫសបានច្រើន រឹងមាំ និងស្លឹកដុះបានឆាប់
- ដាក់ជីលាមកសត្វ មិនទាន់ពុកផុយ បង្កឲ្យកូនបន្លែរលួយ។



ការរៀបចំរង



ការដាក់ជីទ្រាប់បាត

## ការស្រោចទឹកលើរង

- ស្រោចទឹកលើរងដាំឲ្យជោគដល់ខាងក្នុងរងមុនគ្របប្លាស្ទិកឬចំបើងធ្វើឲ្យ៖
  - ✓ ដីត្រជាក់ កូនបន្លែងាយដុះលូតលាស់
  - ✓ កាត់បន្ថយកូនបន្លែអន់ ឬងាប់ក្រោយដាំ។



## ផលប្រយោជន៍នៃការដាំមានគម្រប

របៀបដាំដោយមានគម្របនេះ ដើម្បីបង្កើនបរិមាណសារធាតុ កាបូន ជាសារធាតុសំខាន់ក្នុងដី ជួយបង្កើនជីជាតិដី រក្សាសំណើមក្នុងដីការពារកំដៅថ្ងៃ ការពារខ្យល់ ទប់ស្កាត់សារធាតុសរីរាង្គ មិនឲ្យហូរច្រោះ និងជួយកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ កាត់បន្ថយបរិមាណ ជីប្រើប្រាស់ ជួយបន្សាំការដាំដុះទៅនឹងការប្រែប្រួលអាកាសធាតុ ។

## គ្របរងដាំ

មានប្រសិទ្ធភាពខ្ពស់ ជាមួយប្រព័ន្ធស្រោចស្រព គឺប្រព័ន្ធដំណក់ទឹក ទោះមិនមានប្រព័ន្ធស្រោចស្រពក៏អាចធ្វើការគ្របដីបានដែរ។

- បន្ទាប់ពីដាក់ជីទ្រាប់បាត ស្រោចទឹកឲ្យជោគ ទើបចាប់ផ្តើមគ្របរងបាន។

១.ប្លាស្ទិកគ្របដី៖



- ទាញដុំប្លាស្ទិកបណ្តោយរង ស្រទាប់សដាក់លើ ស្រទាប់ខ្មៅដាក់ក្រោម
- ខ្ទាស់បន្ទះឫស្សី ពីលើប្លាស្ទិកជាប់ នឹងដីនៅតាមគល់ និងចុងរងដាំបន្លែឲ្យញឹក



- ទាញប្លាស្ទិកតាមបណ្តោយរង
- យកបន្ទះឫស្សីខ្ទាស់តាមគែមរងប្រវែង ពី ៣ ទៅ ៤តឹក សម្រាប់ខ្ទាស់១ កន្លែង



- ខ្នាតវាស់វែងចន្លោះគុម្ព
- ចុងខ្នាតចាក់ទម្លុះប្លាស្ទិកសម្រាប់ដៅចោះរណ្តៅដាំកូនត្រសក់ ខ្នាតអាស្រ័យប្រភេទដំណាំ



- ចោះរណ្តៅតាមខ្នាតដែលបានដៅទុក កំប៉ុង មុខកាត់ ១តឹកកន្លះ ដាក់រងើកភ្លើងសម្រាប់ចោះរន្ធ



រងបន្លែដែលបានចោះរណ្តៅត្រៀមដាំកូនបន្លែ



គ្របធូរ ខ្យល់ក្តៅចេញចូលក្នុងរងក្រោមប្លាស្ទិក កូនបន្លែងាប់ និងងាយរហែក



គ្របត្រឹមត្រូវតាមបច្ចេកទេស

## ២. អាចគ្របជាសរីរាង្គ (ចំបើង)

- គ្របចំបើងកម្រាស់ ៦ ទៅ១០សង្ទីម៉ែត្រ

## ការធ្វើទ្រើង

- ធ្វើពីខ្សែអំបោះ ឬ ពីកូនឈើ
- បង្គោលធ្វើទ្រើងឲ្យមាំ
- ធ្វើទ្រើងមុនដាំត្រសក់ ខ្សែទ្រើងដាក់ក្បែរគល់ត្រសក់
- បង្គោលទ្រើង កម្ពស់ ១,៨ ទៅ ២ម៉ែត្រ។



គ្របចំបើងកម្រាស់ ៦ ទៅ ១០សង្ទីម៉ែត្រ



រងបានគ្របចំបើងហើយត្រៀមដាំកូនបន្លែ



ទ្រើងធ្វើពីកូនឈើ

# មេរៀនទី ២: ការធ្វើរោងបណ្តុះកូន និងការបណ្តុះគ្រាប់

## ១. គោលបំណងនៃវគ្គបណ្តុះបណ្តាល

ផ្តល់ចំណេះដឹងដល់សិក្ខាកាមអំពីៈ

- បច្ចេកទេសសង់ រោងបណ្តុះកូនត្រសក់ ការពារសត្វល្អិតចង្រៃ ការឆ្លងជម្ងឺ និងធន់នឹងអាកាសធាតុប្រែប្រួលក្នុងរដូវប្រាំង និងវស្សា
- ការប្រៀបធៀប បច្ចេកទេសត្រាំគ្រាប់ពូជ ឬ ដាក់គ្រាប់ពូជបណ្តុះផ្ទាល់

## ២.ការធ្វើរោងបណ្តុះកូន

- មានពន្លឺថ្ងៃគ្រប់គ្រាន់ មិននៅក្បែរដើមឈើ
- ដំបូលពណ៌ស មានពន្លឺថ្ងៃចាំងចូលកូនបន្លែគ្រប់គ្រាន់
- កម្ពស់ ២ ទៅ ២,៥០ម៉ែត្រ
- គ្របសំណាញ់កាត់ពន្លឺរដូវក្តៅខ្លាំង
- គ្របប្លាស្ទិកពណ៌សរដូវវស្សា
- រានបណ្តុះកូនកម្ពស់ ០,៥ម៉ែត្រពីដី ធ្វើពីឫស្សី ក្តារ
- ហាមក្រាលដី បាវក្រចៅ ឬសម្ភារៈជក់ទឹកពីក្រោម អាចនាំជម្ងឺឆ្លងកូនបន្លែ ឬ ឫសចាក់ហួសកន្ទោង
- គ្របសំណាញ់សត្វល្អិតពណ៌ស




រោងបណ្តុះកូន

❖ **សារៈប្រយោជន៍**

- ការពារកូនដំណាំ ពីការឆ្លងជម្ងឺ និងសត្វល្អិតចង្រៃ
- ជៀសវាងការរលួយកូននៅខែវស្សា កាត់បន្ថយការឆ្លងជម្ងឺហូរតាមដី មកកូនត្រសក់

## ៣.ការបណ្ដុះគ្រាប់

- ដីមានដីជាតិ ១ ភាគ ដីលាមកគោស្ងួត ឬ ដីកំប៉ុស្ដិ៍ ២ ភាគ និងផេះអង្កាម ពី២ ទៅ ៤ភាគ (ផេះអង្កាមត្រាំទឹក ពី៣ ទៅ ៤យប់)
- លាយច្របល់ និងលីងរហូតក្ដៅសព្វទាំងអស់

❖ **សារៈប្រយោជន៍:**

❖ គ្រាប់ងាយដុះ ឬសដុះលូតលាស់ល្អ
❖ កូនបន្លែស្រូបជីជាតិគ្រប់គ្រាន់
❖ សម្លាប់មេរោគ បង្កឲ្យកូនបន្លែរលួយ
❖ សម្លាប់គ្រាប់ស្មៅចង្រៃដណ្ដើមជីពីកូនបន្លែ
❖ សម្លាប់ពង សត្វល្អិតចង្រៃក្នុងដីបំផ្លាញគ្រាប់បន្លែ
❖ ដីលីងហើយទុកឲ្យត្រជាក់ដាក់ក្នុងកន្ទោង ឬ ថាសបណ្ដុះ






វិធីរៀបចំលាយល្បាយដីបណ្ដុះ




យកដីបណ្ដុះលីង ហើយដាក់កន្ទោង ឬ ថាសបណ្ដុះ



ស្រោចទឹកឲ្យជោគដីបណ្តុះទើបដាក់គ្រាប់



ដាក់គ្រាប់ពូជ១គ្រាប់ក្នុងប្រឡោះថាសបណ្តុះ ឬ ១កន្ទោង និងរោយដីលប់



រោយដីបណ្តុះពីលើគ្រាប់ទើបស្រោចទឹក



យកថាសបណ្តុះដាក់ក្នុងរោងបណ្តុះ

## ❖ ការថែទាំកូនត្រសក់

- ស្រោចទឹកឲ្យជោគពេលព្រឹក និងថ្ងៃ
- មិនគួរស្រោចនៅម៉ោង ៥ល្ងាច ធ្វើឲ្យដីសើមនៅពេលយប់ គ្រាប់សើមជ្រុល ឫសកូនត្រសក់សើមពេក កូនត្រសក់រលួយ។

# មេរៀនទី ៣: ការដាំកូនត្រសក់

**១. គោលបំណងនៃវគ្គបណ្តុះបណ្តាល** ផ្តល់ចំណេះដឹងដល់សិក្ខាកាមអំពី៖

- បច្ចេកទេសបណ្តុះ និងថែទាំកូនត្រសក់ទទួលបានលទ្ធផលល្អ

**២. ការដាំកូនត្រសក់**

- អាយុ ៧ថ្ងៃ មានស្លឹក ២ពេញលេញ អាចដាំបាន
- ពង្រឹងកូនត្រសក់ បន្ទាប់ពីដុះបាន ២ ទៅ ៣ថ្ងៃ បើកដំបូលឆាងត្រូវពន្លឺថ្ងៃជៀសវាងថ្ងៃត្រង់ បន្ថយស្រោចទឹករហូតដល់ដាំ
    - **អត្ថប្រយោជន៍ ការពង្រឹងកូនត្រសក់៖**
        - ✓ ដើមកូនរឹងមាំល្អ
        - ✓ កូនត្រសក់ស៊ាំអាកាសធាតុខាងក្រៅ
        - ✓ ដាច់ឫសតិចពេលដកកូនដាំ មិនអន់
- ស្រោចទឹកមុនពេលដាំ១ ទៅ ២ម៉ោង
- ដាំកូនត្រសក់នៅពេលរសៀល
- ស្រោចទឹកបញ្ចូលរងពេលព្រឹក កាត់បន្ថយការភាយកំដៅពីរងដែល គ្របប្លាស្ទិច កូនបន្លែងាប់តិចបំផុត
- ដាំត្រសក់ត្រឹមដីកំណើត ឆាប់ដុះលូតលាស់ មិនរលួយគល់កូន។





កូនត្រសក់ក្នុងថាសបណ្ដុះ



ថ្នាលរៀបចំរួចត្រៀមដាំកូនត្រសក់



ម្រាមដៃរុញបាតថាស ដៃម្ខាងទាញដកគល់កូនដំណាំ



ដាំកូនត្រសក់ត្រឹមដីកំណើត កប់លិចដើម ធ្វើឲ្យរលួយកូន

# មេរៀនទី៤ : របៀបស្រោចស្រពដោយប្រព័ន្ធដំណក់ទឹក

## ១.គោលបំណង

ផ្តល់ចំណេះដឹងដល់សិក្ខាកាមអំពី៖

- ការប្រើប្រាស់ប្រព័ន្ធស្រោចស្រពដោយតំណក់ទឹកបន្ទាប់ពីការដាំកូនត្រសក់រួច
- ការគ្រប់គ្រងទឹកសម្រាប់ស្រោចដំណាំនៅរដូវប្រាំង
- ចេះវិធីស្រោចស្រពដោយដំណក់ទឹក និងប្រើប្រាស់សន្សំសំចៃទឹកឲ្យមានប្រសិទ្ធភាព ល្អជាងការដងទឹកស្រោចផ្ទាល់។




មូលដ្ឋានគ្រឹះនៃបច្ចេកទេសតាមបែបសាមញ្ញ

## ២. ការស្រោចដំណាំ

- **រដូវវស្សា:** ស្រោចពេលដាំកូនដំណាំរួច បន្ទាប់ពីគ្មានភ្លៀងធ្លាក់២-៣ថ្ងៃ ត្រូវស្រោចទឹកក្រោយភ្លៀងរួចដើម្បីលាងស្លឹកបន្លែជាប់ដី និងបណ្តលដំណាំបន្លែសម្រាប់រងបន្លែមិនបានគ្របចំបើង និងកៅស៊ូ
- **រដូវប្រាំង:** ស្រោចទឹករៀងរាល់ថ្ងៃ ១ថ្ងៃ ២ដងទៅ ៣ដង (ព្រឹក-ល្ងាច)។

## ៣.សង្ខេបបច្ចេកទេស

- វិធីស្រោចស្រពមានប្រសិទ្ធភាព និងសន្សំសំចៃទឹក
- ការបន្តក់ទឹកឲ្យស្រក់តក់ៗ និងទៀងទាត់ដល់ដីផ្ទាល់តាមបណ្តាញបំពង់ទីប និងទុយោ
- ទឹកដែលមានក្នុងពាង ឬ ធុងចេញស្មើគ្នាចូលដល់ ឫសនៃរុក្ខជាតិ
- ធ្វើឲ្យមានសំណើមល្អបំផុតជុំវិញឫស និងកាត់បន្ថយរំហួតនិងការហូរចេញក្រៅដែលធ្វើឲ្យមានការប្រើប្រាស់ទឹកតិច។

## ៤. គុណសម្បត្តិនៃរបៀបស្រោចស្រពដោយតំណក់ទឹក

- ចំណេញពេលវេលាក្នុងការដាំដំណាំ
- កាត់បន្ថយរំហួត និងការហូរចេញក្រៅធ្វើឲ្យការប្រើប្រាស់ទឹកតិច
- សន្សំសំចៃពេលវេលា និងកម្លាំងពលកម្មសម្រាប់ស្រោចស្រព
- ប្រើប្រាស់ទឹកដោយមានប្រសិទ្ធិភាព
- ងាយស្រួលក្នុងការដាំបន្លែ សម្រាប់ស្ត្រី និងក្រុមគ្រួសារមានកម្លាំងពលកម្មតិច ទៅតាមដី និងទឹកដែលមាន
- រក្សាសំណើមដីបានល្អ កាត់បន្ថយស្មៅដុះ ជួយជំរុញឫសលូតលាស់បានល្អ កាត់បន្ថយសត្វល្អិតចង្រៃ ក្នុងទឹក និងមេរោគផ្សិត

## ៥. របៀបធ្វើ ឬ ប្រើប្រាស់

- សាងសង់ ឬលើកធ្នើរសម្រាប់ដាក់ពាងទឹក/ធុងសាំងកំពស់ ១,៥០ម៉ែត្រ ទៅ ២ម៉ែត្រ
- ចោះទំលុះពាងកំពស់ពីបាត ១តឹក ភ្ជាប់ទុយោភីវីស៊ី ២៧មម និងល្បាយស៊ីម៉ង់ត៍
- ភ្ជាប់ទុយោ ភីវីស៊ី ២៧សម និងវ៉ាន ២៧មម និងកែង ភីវីស៊ី ២៧មម
- ភ្ជាប់ពីកែង និងសុងញី ភីវីស៊ី ២៧មម
- ភ្ជាប់ពី សុងញី ២៧មម និងចម្រោះ (ប្រើស្កុតទឹករុំ ១០ជុំ)
- ភ្ជាប់ពីចម្រោះ និងសុងញីឈ្មោល (៣៤មម- ២៧មម) Bush ១"x ៣/៤"(ប្រើស្កុតទឹករុំ ១០ជុំ)
- ភ្ជាប់ពីសុងញីឈ្មោល ផ្នែកខាងឈ្មោល ៣៤មម និងសុងញី ៣៤មម ចេញសុង ២៥មម
- ភ្ជាប់ពីសុង ២៥មមនិងទុយោភីអី ២៥មម (ត្រូវទុកទុយោហាលថ្ងៃ ឬកំដៅឲ្យទន់ទើបភ្ជាប់)
- ភ្ជាប់ពីទុយោភីអី ២៥មម និងតេ ភីអី ២៥មម (ត្រូវទុកទុយោហាល ឬកំដៅ ឲ្យទន់ទើបងាយភ្ជាប់វា)
- ភ្ជាប់ពីតេ ភីអី ២៥មម ទាំងសងខាង និងទុយោភីអី ២៥មម (ត្រូវទុក ទុយោហាល ឬកំដៅឲ្យទន់ទើបងាយភ្ជាប់វា)
- តាមរងនីមួយៗ ត្រូវភ្ជាប់ និងតេ២៥មម ចេញ ២១មម ឈ្មោល
- ភ្ជាប់ពីតេ ២៥មម ចេញ ២១មម ឈ្មោល និងតំណញី ២១មម (អាចភ្ជាប់និងដោះបាន)
- ភ្ជាប់ពីតំណញី ២១មម និងទុយោតំណក់ទឹក ១៦មម និងចុងទុយោដំណក់នីមួយៗ ត្រូវបត់មិនឲ្យទឹកចេញទើបស្រក់តាមរន្ធនីមួយៗ
- នៅផ្នែកខាងចុងទុយោមេ ២៥មម សងខាង ត្រូវបិទដោយឆ្នុក ២៥មម (ត្រូវទុកទុយោហាលកំដៅឲ្យទន់ទើបងាយភ្ជាប់វា)។

ពាង ឬធុងស្តុកទឹក ត្រូវភ្ជាប់វ៉ានសម្រាប់លាងសម្អាត ពេលទឹកមិនស្អាតកំឡុង ពេលស្រោចទឹក ត្រូវកំណត់ពេលតាមប្រភេទដំណាំ និងតម្រូវការទឹករបស់ដំណាំនីមួយៗ។

- អាចបញ្ចូលជីដល់ដំណាំ តាមការបញ្ចូលទឹកដោយប្រើជីកំប៉ុស្តិ៍ទឹក។




អនុវត្តបច្ចេកទេសប្រព័ន្ធស្រោចស្រពដោយដំណក់ទឹក

# មេរៀនទី៥ : ការថែទាំ

## ១.គោលបំណង

ផ្តល់ចំណេះដឹងដល់សិក្ខាកាមអំពីៈ

- វិធានការថែទាំ និងការប្រើថ្នាំពុលផ្សំពីរុក្ខជាតិសម្លាប់សត្វល្អិត លើដំណាំត្រសក់

## ២. ការថែទាំ

### ការដាក់ជីបំប៉ន ដោយប្រើជីកំប៉ុស្តិ៍ទឹក

- ប្រើជីកំប៉ុស្តទឹកក្រោយការដាំហើយ រយៈពេល ១០ថ្ងៃ ប្រើរៀងរាល់ ៧ ថ្ងៃម្តង
- កំប៉ុស្តទឹក១លីត្រ លាយទឹក២០លីត្រ ឬមួយធុងស្តេចត្រូ ស្រោចលើដំណាំ ឬ លាយទឹកបង្ហូរតាមប្រព័ន្ធទ្រីប បន្ទាប់មកស្រោចទឹកមួយសារទៀត
- ប្រើជីទឹក ធ្វើឲ្យដីធូរល្អ ផ្តល់សារធាតុចិញ្ចឹមដល់ដំណាំ និងជួយរក្សាសំណើមក្នុងដី។

### ការដាក់ជីបំប៉ន ដោយប្រើជីកសិកម្ម

- ដាក់ជី អ៊ុយរ៉េ  ១ខាំ លាយទឹក ២០លីត្រ បំប៉នឱ្យទៀងទាត់រៀងរាល់៧ ថ្ងៃម្តង បន្ទាប់ពីដាំកូនបន្លែហើយ
- ចំពោះដីខ្សាច់  ត្រូវដាក់ជីឱ្យញឹកញាប់ តែក្នុងបរិមាណតិចជាងដី ដែលមានល្បាយច្រើនជាងខ្សាច់
- ដាក់ជីហើយត្រូវស្រោចទឹក (ជៀសវាងដាក់ជីនៅពេលថ្ងៃក្តៅ)។



រណ្តៅកប់ជីប៉ប៉ន



បង្ហូរជីតាមបំពង់ស្រោចស្រព

## រៀបដាក់ជីក្នុងរងគ្របប្លាស្ទិកគ្របដី និងចំបើង

- ឈើបុកជារណ្តៅ លើរងគ្របចំបើង ឬប្លាស្ទិក ជម្រៅ ៥សង្ទីម៉ែត្រ ដាក់ជីតាមរណ្តៅ
- រណ្តៅដាក់ជីរាក់ល្មម ឫសដំណាំចាប់យកជីនោះបាន។

## ការស្រោចទឹក

- ស្រោចទឹកពេលព្រឹក បញ្ចូលទឹកតាមចន្លោះរង។ ស្រោចពេលថ្ងៃត្រង់ ឬពេលល្ងាច (ដីសើមនៅពេលយប់) ធ្វើឲ្យត្រសក់ រលួយ ឬ រលាកដើម
- ស្រោចទឹកទៀងទាត់ មិនត្រូវឲ្យដីស្ងួតបន្ទាប់ពីដាំកូនត្រសក់
- កូនដំណាំត្រូវការទឹក ជីសម្រាប់ដុះលូតលាស់ ឫស ដើម ស្លឹក ផ្កា ផ្លែ
- នៅក្បែគល់ស្ងួត(មិនអាចលុញជាដុំមូលបាន) ត្រូវស្រោចទឹកបន្ថែម
- ដីនៅក្បែរគល់ត្រសក់សើមខ្លាំង មិនត្រូវដាក់ទឹក
- ទឹកដក់ច្រើនពេកធ្វើឲ្យត្រសក់រលួយឫស ឬ ងាប់ដើម។



ចង្អូរសម្រាប់បញ្ចូលទឹក

## ការចងដើម និង ការកាត់ស្លឹក

- ចងដើមត្រសក់ជាប់នឹងខ្សែសំណាញ់ទ្រើង ឬ ទ្រើងឫស្សី ដើម្បីទប់ដើមឱ្យមានលំនឹងឡើងទ្រើង នៅរដូវមានខ្យល់
- កាត់ស្លឹកនៅជាប់នឹងដីចេញ ជៀសវាងការខ្ទាតដីប៉ះប្រឡាក់ នាំឱ្យឆ្លងជម្ងឺ។



កាត់សន្លឹកផ្នែកខាងក្រោម



ចងដើមជាប់នឹងសំណាញ់ទ្រើង

❖ **ការជំរះស្មៅ**

- ជំរះស្មៅឲ្យបានស្អាត ទោះបីជារងគ្របចំបើង ឬ គ្របប្លាស្ទិចក៏ដោយ។
- ស្មៅនៅតាមចន្លោះរង ឬ ក្នុង ចំការ គឺជាជម្រកសត្វល្អិតចង្រៃបំផ្លាញ និងជាភ្នាក់ងារចម្លងជម្ងឺដល់ដំណាំ។

## ៣. សត្វល្អិត និងជម្ងឺ

### ជម្ងឺផ្សិត មេរោគផ្សិត

- កើត លើឫស គល់ ស្លឹក និង ផ្កា
- កើតលើឫស ហៅជម្ងឺពុកឫស កើតលើគល់និងស្លឹកហៅថាជម្ងឺស្លឹកម្សៅ និងជម្ងឺទុំស្លឹក
- ប្រើថ្នាំធម្មជាតិសម្រាប់ការពារ ជម្ងឺផ្សិត

### ជម្ងឺបង្កឡើងដោយវីរុស

- ចៃ មមាច មមង់ រុយស ពីងពាងក្រហម ជាអ្នកបង្កឲ្យកើតជម្ងឺរួញ ហៅថាមូសាអ៊ិចវីរុស មានជម្ងឺនេះ ត្រូវដកដើមចេញ

### វត្ថមានសត្វល្អិតចង្រៃសំខាន់ៗ

មាន៣ប្រភេទស៊ីបំផ្លាញ ស្លឹក ដើម ផ្កា និងផ្លែ:

- **អណ្ដើកមាសកង់វងវងពណ៌លឿង**: ស៊ីបំផ្លាញត្រួយ ស្លឹកដំបូង ផ្កាឈ្មោល ផ្កាញី
- **ដង្កូវកាត់គល់**: ស៊ីកាត់គល់ត្រសក់នៅពេលយប់ ពេលថ្ងៃលាក់ខ្លួនក្នុងដីជំរៅប្រមាណ ៤-៥ស.ម ពីគល់ដំណាំ ១៨-២៥ ស.ម
- **ដង្កូវមូលត្រួយ** : ស៊ីត្រួយត្រសក់ខ្ចីៗ និងផ្កាត្រសក់

## ៤. វិធានការណ៍សម្លាប់សត្វល្អិតបំផ្លាញដំណាំត្រសក់

ប្រើថ្នាំពុលផ្សំពីរុក្ខជាតិសម្លាប់សត្វល្អិត រំដេង សំបក និងផ្លែស្លែង គល់ស្លឹកគ្រៃ រល្លីបណ្ដូលពេជ្រ ស្លឹក និងសំបកស្ដៅ ថ្នាំខ្លាំង លាមកមាន់ លាមកគោ ទឹកនោមមនុស្ស។ ត្រាំរយៈពេល ១ខែ ។

- ប្រើកំចាត់ ដង្កូវ អណ្ដើកមាស ។ លាយទឹក ២០លីត្រ ជាមួយថ្នាំ ១លីត្រ បាញ់ ២-៣ ដង
- ប្រើលើកទី២ ១,៥លីត្រ លាយទឹក ២០លីត្រ
- អាចយកចំបើង ជ្រលក់ទឹកថ្នាំប្រស់លើដំណាំដែលមានសត្វល្អិតបំផ្លាញ រលាស់ ម៉ោង ៤-៥ ល្ងាច ។



រំដេង



ស្លឹកគ្រៃ



ក្អមពាង



លាមកគោក



លាមកមាន់

# មេរៀនទី៦ : បច្ចេកទេសគ្រប់គ្រង ក្រោយការប្រមូលផលត្រសក់

## ១.គោលបំណង

ផ្ដល់ចំណេះដឹងដល់សិក្ខាកាមអំពីៈ

- ការចាត់ចំណាត់ថ្នាក់គុណភាពផ្លែត្រសក់ និងការវេចខ្ចប់ក្រោយពេលប្រមូលផល។

## ២. ការប្រមូលផល

- ទំហំផ្លែត្រសក់បេះទៅតាមតម្រូវការទីផ្សារ និងបេះផ្លែនៅពេលព្រឹក ដោយប្រើកន្ត្រៃ
- កាត់ទងត្រសក់ដែល មានទំហំល្មម
- បេះផ្លែដាក់ក្នុងសម្ភារៈ ដែលមានផ្ទៃរលោង ដើម្បីជៀសវាងការកកិត និង ជាំផ្លែ
- ចំណាត់ថ្នាក់គុណភាពផ្លែត្រសក់ ជាលេខ ១, ២, ៣
- ប្រកចង់ដែលមានបរិមាណសមស្របមានគុណភាពស្វិតទន់
- ថង់ត្រូវចោះរន្ធតូចៗ ដើម្បីឲ្យមានខ្យល់ចេញចូល កុំឱ្យក្ដៅស្អោក
- ជៀសវាងប្រកត្រសក់ច្រើនហួសបរិមាណ
- ហាមប្រើសម្ភារៈគ្មានខ្យល់ចេញចូលព្រោះវាធ្វើឲ្យត្រសក់ខូចគុណភាព (ទន់ ប្រែពណ៌លឿង និង ងាយរលួយ)។



របៀបប្រមូលផល



ចំណាត់ថ្នាក់គុណភាព ត្រសក់លេខ១



ចំណាត់ថ្នាក់គុណភាព ត្រសក់លេខ២



ការវេចខ្ចប់មិនបានត្រឹមត្រូវ



ការវេចខ្ចប់បានត្រឹមត្រូវល្អ



ដាក់ក្នុងឡាំងជ័រដឹកជញ្ជូនតាមម៉ូតូទៅផ្សារ

# មេរៀនទី ៧ : ការបញ្ចូលរបៀបថ្មី លើគោលគំនិត អាជីវកម្មកសិកម្មខ្នាតតូចផ្នែកដំណាំបន្លែ

**តើត្រូវធ្វើដូចម្តេចខ្លះដើម្បីចាប់ផ្តើមដាំដំណាំបន្លែ?**

### ការពិពណ៌នាជាទូទៅ

បន្លែជាប្រភពផ្តល់វីតាមីន ។ មនុស្ស និងសត្វត្រូវការបរិភោគ បន្លែគ្រប់មុខ ជាចាំបាច់សម្រាប់ការធំធាត់ ការបន្តពូជ និងសុខភាពល្អ ទាំងអស់នេះហើយដែលជា តម្រូវការក្នុងការបង្កើនការដាំដំណាំបន្លែ ប្រកបដោយទិន្នផលខ្ពស់ និងគុណភាពល្អ ។

### ១. ផ្ទៃដីសម្រាប់ដាំបន្លែ

- ផ្ទៃដីសម្រាប់ដាំបន្លែ ០,៥ហិកតា/១ហិកតា (អាស្រ័យកសិករមាន)

### ២. វត្ថុធាតុដើម និងសំភារៈ សម្រាប់ការដាំបន្លែ (ផែនការអាជីវកម្ម)

# តារាងផែនការអាជីវកម្ម នៃការដាំបន្លែ

កាលបរិច្ឆេទសចាប់ផ្តើមអាជីវកម្ម៖.....................................................

**១.ចំណាយថ្លៃវត្ថុធាតុដើម**

| រាយមុខទំនិញ | ឯកតា | ចំនួន | តម្លៃ១ឯកតា(រៀល) | តម្លៃសរុប(រៀល) |
|---|---|---|---|---|
| គ្រាប់ពូជបន្លែ | កញ្ចប់ | | | |
| ជីកសិកម្ម | បាវ | | | |
| ជីកំប៉ុស្ត | គក្រ | | | |
| | | | | |
| | | | | |
| | | | | |
| សរុបចំណាយថ្លៃវត្ថុធាតុដើម | | | | |

## ២.ចំណាយថ្លៃឧបករណ៍/សម្ភារៈ

| រាយមុខឧបករណ៍/សម្ភារៈ | ឯកតា | ចំនួន | តម្លៃ១ឯកតា(រៀល) | តម្លៃសរុប(រៀល) |
|---|---|---|---|---|
| ពាងទឹកធំ ឬ ធុងស្តុកទឹកធំ | ចំនួន | | | |
| កូនពាងទឹក | ចំនួន | | | |
| ទ្រុងជីកំប៉ុស្ត | ទ្រុង | | | |
| រនាស់បំបែកដី | ចំនួន | | | |
| ម៉ាស៊ីនបូមទឹក | ចំនួន | | | |
| គោយន្តភ្ជួរដី | ចំនួន | | | |
| ប្លាស្ទិចគ្របថ្នាលបន្លែ | ម៉ែត្រ | | | |
| បំពង់ទីបប្លាស្ទិច/ចម្រោះទឹក/ក្បាលរ៉ូប៊ីនេ/ទុយោនាំទឹក | សរុប | | | |
| | | | | |
| | | | | |
| | | | | |
| **សរុបចំណាយថ្លៃឧបករណ៍/សម្ភារៈ** | | | | |

**សរុបចំណាយទាំងអស់** ……………………………. + ……………………………… = ………………………………

## ៣. ផែនការថវិកា សម្រាប់ប្រតិបត្តិការកសិកដ្ឋានរបស់អ្នក

- លទ្ធភាពថវិកាដែលមាន សម្រាប់ដំណើរការកសិដ្ឋាន ដាំដំណាំបន្លែ៖
  - ✓ ថវិកាដែលមានផ្ទាល់ខ្លួន ចំនួនដែលខ្វះត្រូវខ្ចីពីសាច់ញាត្តិ ឬស្ថាប័នមីក្រូហិរញ្ញវត្ថុ ឬសហគមន៍ (អាស្រ័យទំហំនៃការដាំ)

## ៤. សម្រេចចិត្តជ្រើសរើស ប្រភេទបន្លែដែលត្រូវដាំ (តម្រូវការនៅលើទីផ្សារខ្ពស់)

- ធាតុអាកាស៖ គ្រាប់ដំណាំដែលត្រូវទៅនឹងអាកាសធាតុ ដាំលូតលាស់ល្អ ពេលវេលាប្រមូលផល
- ពេលវេលា និងកម្លាំងពលកម្មសមស្រប
- ប្រភេទបន្លែអ្វីដែលត្រូវដាំ
- ជៀសវាងដំណាំដែលស្មុយរលួយ
- ការប្រមូលផល និងលក់ផលិតផលរបស់អ្នកជាបន្ទាន់
- ចំណេះដឹងបច្ចេកទេស និងការដាំដំណាំ
- សិក្សាអំពីធនធានដែលមាន (ប្រភពទឹក សម្រាប់កសិដ្ឋានបន្លែ)

## ៥. អ្នកផ្គត់ផ្គង់គ្រាប់ពូជ និងកូនបន្លែ

- ទិញពីថ្នាលបណ្តុះកូនបន្លែឯកជន
- ទិញពីសហគមន៍មូលដ្ឋាន
- ផលិតគ្រាប់ពូជ និងកូនបន្លែ ដោយខ្លួនឯង
- ទិញគ្រាប់ពូជ ពីកសិដ្ឋានផលិតពូជបន្លែ របស់រាជរដ្ឋាភិបាល
- ទិញពីអ្នកផ្គត់ផ្គង់ដែលមានអាជ្ញាបណ្ណនាំចូលពូជបន្លែជាផ្លូវការ

## ៦. ការយល់ដឹងពីការគាំទ្រ ការដាំបន្លែរបស់អ្នក

- ការពិភាក្សាជាមួយ ភ្នាក់ងារផ្សព្វផ្សាយស្រុក ឬភ្នាក់ងារផ្សព្វផ្សាយឃុំ  ដែលនៅជិតអ្នកបំផុត ពីជម្ងឺបន្លែ និងការថែទាំដំណាំបន្លែ
- កត្តាដែលមានឥទ្ធិពលលើការផ្គត់ផ្គង់
- ប្រតិទិននៃការដាំបន្លែ តម្រូវការទីផ្សារ និងតម្លៃ

# ប្រតិទិនរដូវកាល ដាំដុះបន្លែ តម្រូវការទីផ្សារ និងតម្លៃ

| ល.រ | ឈ្មោះដំណាំ | ប្រតិទិនរដូវកាល ដាំដុះបន្លែ | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
| **ក** | **បន្លែដាំខែវស្សា** | | | | | | | | | | | | |
| ១ | ត្រសក់ទ្រើង | | | | | | | | | | | | |
| ២ | សណ្តែកគួរ | | | | | | | | | | | | |
| ៣ | ត្រឡាច | | | | | | | | | | | | |
| ៤ | ត្រប់ | | | | | | | | | | | | |
| ៥ | ត្រកួន | | | | | | | | | | | | |
| ៦ | ល្ពៅ | | | | | | | | | | | | |
| ៧ | ល្ហុង | | | | | | | | | | | | |
| ៨ | ចេក | | | | | | | | | | | | |
| **ខ** | **បន្លែដាំខែប្រាំង** | | | | | | | | | | | | |
| ១ | ស្ពៃក្តោប | | | | | | | | | | | | |
| ២ | ខាត់ណាផ្អែម | | | | | | | | | | | | |
| ៣ | ត្រកួន | | | | | | | | | | | | |
| ៤ | ប៉េងប៉ោះ | | | | | | | | | | | | |
| ៥ | ស្ពៃជើងទា | | | | | | | | | | | | |
| ៦ | ត្រសក់ | | | | | | | | | | | | |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៧ | សណ្តែកគួរ | | | | | | | | | | | | |
| ៨ | ត្រឡាច | | | | | | | | | | | | |
| ៩ | ននោង | | | | | | | | | | | | |
| ១០ | ស្ដែចង្កិះ | | | | | | | | | | | | |
| **គ** | **ពត៌មានទីផ្សារ** | | | | | | | | | | | | |
| ១ | រាំងមិនអាចដាំបាន | | | | | | | | | | | | |
| ២ | បន្លែលក់បានថ្លៃ | | | | | | | | | | | | |
| ៣ | បន្លែសំបូរ ថោក អ្នកដាំច្រើន | | | | | | | | | | | | |
| **ឃ** | **ការខារយេនឌ័រ** | | | | | | | | | | | | |
| ១ | បុរស ស្ត្រី ស្ទូងដក | | | | | | | | | | | | |
| ២ | បុរស ស្ត្រីដាំបន្លែ រួចការងារ ធ្វើស្រែ | | | | | | | | | | | | |
| ៣ | បុរស ស្ត្រី ច្រូតកាត់ | | | | | | | | | | | | |

## ៨. ការផ្គត់ផ្គង់ទីផ្សារ

| ល.រ | ប្រភពអ្នកទិញ | ប្រតិទិន | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
| ១ | អ្នកប្រើប្រាស់ក្នុងស្រុក | | | | | | | | | | | | |
| ២ | ផ្សារក្នុងស្រុកគោលដៅ | | | | | | | | | | | | |
| ៣ | លក់រាយជាយផ្លូវ | | | | | | | | | | | | |
| ៤ | ផ្សាររបស់កសិករ | | | | | | | | | | | | |
| ៥ | ហាងនៅក្នុងស្រុក | | | | | | | | | | | | |
| ៦ | ភោជនីយដ្ឋានក្នុងស្រុក | | | | | | | | | | | | |
| ៧ | សណ្ឋាគារ | | | | | | | | | | | | |
| ៨ | ផ្ទះលក់ចាប់ហួយ | | | | | | | | | | | | |
| ៩ | ផ្សារទំនើប | | | | | | | | | | | | |

## ៩. ផ្លូវថ្នល់ក្នុងការទំនាក់ទំនងទៅផ្សារ

- ប្រជាជនអាចចូលទៅដល់តំបន់របស់អ្នក
- អាចដឹកនាំផលិតផលរបស់អ្នកទៅផ្សារ
- អ្នកទិញអាចមកមើលកសិដ្ឋាន ឬសួនបន្លែរបស់អ្នក

# តារាង ការវិភាគចំណូលចំណាយ ក្នុងការដាំបន្លែ

| រាយមុខទំនិញ | ឯកតា | ចំនួន | តម្លៃ១ឯកតា(រៀល) | តម្លៃសរុប(រៀល) |
|---|---|---|---|---|
| ១.ចំណាយផលិតកម្ម | | | | |
| ក.ថ្លៃវត្ថុធាតុដើម | | | | |
| គ្រាប់ពូជបន្លែ | កញ្ចប់ | | | |
| ជីកសិកម្ម | បាវ | | | |
| ជីកំប៉ុស្ត | គក្រ | | | |
| | | | | |
| | | | | |
| សរុបចំណាយថ្លៃវត្ថុធាតុដើម | | | | |
| ខ.ថ្លៃឧបករណ៍/ សម្ភារៈ | | | | |
| ពាងទឹកធំ ឬ ធុងស្តុកទឹកធំ | ចំនួន | | | |
| កូនពាងទឹក | ចំនួន | | | |
| ទ្រុងជីកំប៉ុស្ត | ទ្រុង | | | |
| រនាស់បំបែកដី | ចំនួន | | | |
| ម៉ាស៊ីនបូមទឹក | ចំនួន | | | |
| គោយន្តភ្ជួរដី | ចំនួន | | | |
| ប្លាស្ទិចគ្របថ្នាលបន្លែ | ម៉ែត្រ | | | |
| បំពង់ទីបប្លាស្ទិច/ចម្រោះទឹក/<br>ក្បាលរូប៊ីនេ/ទុយោនាំទឹក | សរុប | | | |
| | | | | |
| | | | | |
| សរុបចំណាយថ្លៃឧបករណ៍/សម្ភារៈ | | | | |

| | | | | |
|---|---|---|---|---|
| គ.ថ្លៃពលកម្ម | | | | |
| ថ្លៃពលកម្មថែទាំបន្លែ និងប្រមូលផល | នាក់/ថ | | | |
| | | | | |
| សរុបរងថ្លៃពលកម្ម | | | | |
| សរុបចំណាយផលិតកម្ម (ថ្លៃវត្ថុធាតុដើម + សម្ភារៈ + ពលកម្ម) | | | | |
| ២.ចំណូល(ផលិតផលដែលសម្រេចបាន) | | | | |
| ស្ពៃ | គក្រ | | | |
| ត្រសក់ | គក្រ | | | |
| ម្រះ | គក្រ | | | |
| ត្រប់ | គក្រ | | | |
| | | | | |
| សរុបរងចំណូលផលិតកម្ម | | | | |
| ៣.ការប្រើប្រាស់ក្នុងគ្រួសារ | | | | |
| ត្រសក់ | | | | |
| | | | | |
| សរុបរងការប្រើប្រាស់ក្នុងគ្រួសារ | | | | |
| ៤.បរិមាណ ទុកពូជ | | | | |
| សណ្តែកគួរ | | | | |
| ត្រប់ | | | | |
| | | | | |
| សរុបរងបរិមាណទុកពូជ | | | | |
| សរុបចំណេញ = ចំណូលផលិតកម្ម -ចំណាយផលិតកម្ម | | | | |
| សរុបប្រាក់ចំណេញសុទ្ធ= ចំណេញ -(ប្រើប្រាស់ក្នុងគ្រួសារ + ទុកពូជ) | | | | |

បញ្ហាកើតមានក្នុងការដាំដំណាំបន្លែ..........................................................................................................................................

...........................................................................................................................................................................................

# ឯកសារយោង

១.សៀវភៅកសិករ កម្រងបច្ចេកទេសកសិកម្មល្អៗ ធន់ទៅនឹងអាកាសធាតុប្រែប្រួលខែវិច្ឆិកា ឆ្នាំ ២០១៥។ អង្គការ Action Aid, PIN, Save the Children, Oxfam និងនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម។

២. ឯកសារបណ្តុះបណ្តាលស្តីពី បច្ចេកទេស ដំណាំបន្លែ ឈើហូបផ្លែ និង ការគ្រប់គ្រងក្រោលពេលប្រមូលផល គម្រោងភាពជាអ្នកដឹកនាំផ្នែកសេដ្ឋកិច្ចសម្រាប់ស្ត្រីជនបទ (LEL) ។ អង្គការឃែរកម្ពុជា ខែមិថុនា ឆ្នាំ ២០១៤។

៣. សៀវភៅណែនាំបច្ចេកទេស ផលិតកម្មដំណាំបន្លែ អគ្គនាយកដ្ឋានកសិកម្ម/នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម និង ក្រុមហ៊ុន អ៊ីស្ត វេស្ត ស៊ីដ អ៊ីនធើណេសិនណល (East –West Seed International) ខែ ធ្នូ ឆ្នាំ ២០១៤។

៤.គម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូចតំបន់បឹងទន្លេសាប ( TSSD )។

## រៀបរៀង និងបោះពុម្ពលើកទី១ ឆ្នាំ២០១៧ ដោយៈ

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម ក្រោមមូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍកសិកម្ម(IFAD) និងឧបត្ថម្ភពីរាជរដ្ឋាភិបាលកម្ពុជា
អាសយដ្ឋានៈ # ២០០ផ្លូវនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
(ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ)
លេខទូរស័ព្ទៈ ០២៣ ២២ ១១ ២០
គេហទំព័រៈWWW.ASPIREKH.ORG